ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៤៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារ
## ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា និង សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់ ស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា និងសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់ ស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ដែលមានសមាសភាព ដូចខាងក្រោម៖

១- ឯកឧត្ដម **ឡាំ ជា** រដ្ឋលេខាធិការ **ប្រធាន**

២- ឯកឧត្ដម **ង ឧុឌ្ឍី** អនុរដ្ឋលេខាធិការ **អនុប្រធាន**

៣- ឯកឧត្ដម **ស៊ុម សុខម្ភ** អនុរដ្ឋលេខាធិការ **អនុប្រធាន**

៤- ឯកឧត្ដម **អ៊ុច ចាន់ណុរ៉ា** អនុរដ្ឋលេខាធិការ **អនុប្រធាន**

៥- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ជ៉ាង រ៉ាស៊ី** អនុប្រធានក្រុមប្រឹក្សានីតិកម្ម **សមាជិក**

៦- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ស្វាយ ចាន់ដា** អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា **សមាជិក**

៧- ឯកឧត្ដម **ស៊ី ថរិន** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល **សមាជិក**

៨- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ដាត សុដានិត** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ **សមាជិក**

៩- ឯកឧត្ដម **សុខ លីនណា** អគ្គាធិការរងនៃអគ្គាធិការដ្ឋាន **សមាជិក**

១០- ឯកឧត្ដម ឧត្ដមអគ្គានុរក្សថ្នាក់លេខ១ **សន កែវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ **សមាជិក**

១១- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **សំ បូរ** អគ្គនាយករងនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង **សមាជិក**

១២- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **អ៊ឹម ប្រុណិតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម **សមាជិក**

១៣- លោកជំទាវ ឧត្ដមសេនីយ៍ទោ **រ៉េន សិរីលក្ខិណា** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) **សមាជិកា**

១៤- ឯកឧត្ដម ឧត្ដមសេនីយ៍ទោ **សាង សុធន** អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ **សមាជិក**

១៥- ឯកឧត្ដម ឧត្ដមសេនីយ៍ទោ **ប៉េង គន់** អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ **សមាជិក**

១៦- លោកវរសេនីយ៍ឯក **ខេង ប៉ូលីដា** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ **សមាជិក**

១៧- លោកវរសេនីយ៍ឯក **ជា សារុំ** នាយការិយាល័យនីតិកម្ម នាយកដ្ឋានរដ្ឋបាលសរុបនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ **សមាជិក។**

**ប្រការ២.-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា និងសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត
- ស្រាវជ្រាវ រៀបចំ និងចងក្រងឯកសារពាក់ព័ន្ធ បម្រើឱ្យការពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈខាងលើ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារ គោរពជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច និងផ្តល់មតិដឹកនាំ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិក-សមាជិកា នៃក្រុមការងារ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីចាត់ចែងកិច្ចការតាមភារកិច្ចរបស់ខ្លួន និងត្រូវអនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីប្រធានក្រុមការងារ។

**ប្រការ៤.-**

អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ